១០–លោក **អេឃ តីមឃាន** ប្រធានការិយាល័យគ្រប់គ្រងទុន និងវិនិយោគទុនក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ សមាជិក

១១–លោក **ឃិត ម៉ុណ្ណា** អនុប្រធានមជ្ឈមណ្ឌលបច្ចេកទេសក្រសួងសាធារណការ និង ដឹកជញ្ជូន សមាជិក

១២–លោក **រស់ ម៉ូរ៉ាត** ស្ថាបត្យករនៃទីស្តីការគណៈរដ្ឋមន្ត្រី សមាជិក

**មាត្រា ២** : គណៈកម្មការនេះមានភារកិច្ចពិនិត្យ និង ជ្រើសរើសនូវក្រុមហ៊ុនវិនិយោគទុនសមស្របសំរាប់ព្រលានយន្តហោះពោធិចិនតុងលើរូបមន្ត « សាងសង់ធ្វើអាជីវកម្មប្រគល់វិញ ឬ **B.O.T** » ដើម្បីលើកជូនរាជរដ្ឋាភិបាលសំរេច ។

**មាត្រា ៣** : ក្រោយពីការជ្រើសរើសក្រុមហ៊ុនវិនិយោគទុនព្រលានយន្តហោះពោធិចិនតុងត្រូវបានសំរេចដោយរាជរដ្ឋាភិបាលហើយ គណៈកម្មការមានភារកិច្ចសិក្សារៀបរៀងកិច្ចសន្យា ( **Contract** )ដើម្បីបណ្តោះនៅការអនុវត្តន៍ ។

**មាត្រា ៤** : សហរដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសាធារណការ និង ដឹកជញ្ជូន រដ្ឋមន្ត្រី ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និងរដ្ឋមន្ត្រី រដ្ឋលេខាធិការក្រសួង និងស្ថាប័នពាក់ព័ន្ធ និងសាមីជនដែលមានឈ្មោះក្នុងមាត្រា ១ ត្រូវអនុវត្តអនុក្រឹត្យនេះ ចាប់ពីថ្ងៃឡាយព្រះហស្តលេខា និង ចុះហត្ថលេខានេះតទៅ ។

| | |
|---|---|
| នាយករដ្ឋមន្ត្រីទី ១ | នាយករដ្ឋមន្ត្រីទី ២ |
| ព្រះហស្តលេខា និង ត្រា | ហត្ថលេខា និង ត្រា |
| **នរោត្តម រណឫទ្ធិ** | **ហ៊ុន សែន** |

* * *

រាជធានីភ្នំពេញ , ថ្ងៃទី ២៧ ខែ មិថុនា ឆ្នាំ ១៩៩៥

**អនុក្រឹត្យលេខ : ៥៣ អនក្រ.បក**

**ស្តីពីការប្រកាសទ្រព្យសម្បត្តិរដ្ឋ**

– បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ ១៩៩៣

- បានឃើញព្រះរាជក្រឹត្យ ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ ន ស.រកត-១០-៩៤ -៨៣ ចុះថ្ងៃទី ២៤ ខែ តុលា ឆ្នាំ១៩៩៤ ស្តីពីការកែសំរួលសមាសភាពរាជរដ្ឋាភិបាល .
- បានឃើញព្រះរាជក្រម ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ស្តីពីការរៀបចំ និង ប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រី
- យោងតាមការចាំបាច់

**សំរេច**

**មាត្រា ១ :** យោងតាមស្មារតីមាត្រា ៥៨ នៃរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា កោះតីជាទ្រព្យសម្បត្តិរបស់រដ្ឋ ។

**មាត្រា ២ :** ក្នុងន័យនេះ ដីដែលដុះចាស់ ឬថ្មីជាកោះ នៅសមុទ្រ ទន្លេ ព្រែក ស្ទឹង បឹងបួរ ទូទាំងព្រះរាជាណាចក្រកម្ពុជា ត្រូវប្រកាសថាជាទ្រព្យសម្បត្តិរបស់រដ្ឋ ហើយមិនអនុញ្ញាតអោយឯកជន ឬ សមូហភាពណាប្រកាសជាកម្មសិទ្ធិផ្ទាល់ខ្លួនឡើយ ។

**មាត្រា ៣ :** សហរដ្ឋមន្ត្រី ទីស្តីការគណៈរដ្ឋមន្ត្រី សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ព្រមទាំងស្ថាប័នពាក់ព័ន្ធ ត្រូវអនុវត្ត អោយសំរេច តាមអនុក្រឹត្យនេះរៀង ៗ ខ្លួន ចាប់តាំងពីថ្ងៃ ឡាយព្រះហស្តលេខា និងចុះហត្ថលេខាតទៅ ។

| នាយករដ្ឋមន្ត្រីទី ១ | នាយករដ្ឋមន្ត្រីទី ២ |
|---|---|
| ព្រះហស្តលេខា និង ត្រា | ហត្ថលេខា និង ត្រា |
| **នរោត្តម រណឫទ្ធិ** | **ហ៊ុន សែន** |

* * *

រាជធានីភ្នំពេញ, ថ្ងៃទី ២៨ ខែ មិថុនា ឆ្នាំ ១៩៩៥

**អនុក្រឹត្យលេខ ៥៤ អនក្រ.បក**

**ស្តីពីកិច្ចសន្យា និង កិច្ចព្រមព្រៀងពាណិជ្ជកម្ម ឬ ការខ្ចីបុលដែលទាក់ទង និង ចំណាយថវិការដ្ឋ**

**រាជរដ្ឋាភិបាល**